00613326

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

លេខ/No: D427/4/2

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស<br>(អបជ ~~៩៩~~, ១០៤ និង ២ ទៀតមិនមានលេខសម្គាល់) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 06 / 10 / 2010
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

**សំណើរបស់សហព្រះរាជអាជ្ញា**
**ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់**
**នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ**
**ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់**

---

**<u>អ្នកដាក់ឯកសារ:</u>**

*សហព្រះរាជអាជ្ញា:*
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Anees AHMED

**<u>អ្នកទទួលឯកសារ:</u>**

*អង្គបុរេជំនុំជម្រះ:*
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING QC
ចៅក្រម ន័យ ធុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

*មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:*
លោក គឹម ម៉េងឃី
កញ្ញា មុំ សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី Elizabeth RABESANDRATANA
លោកស្រី Annie DELAHAIE
លោកស្រី Fabienne TRUSSES-NAPROUS

00613327



| | |
|---|---|
| ***មេធាវីដើមបណ្តឹងឧទ្ធរណ៍:*** | លោក នី ចាន់ឌី |
| លោក អាង ឧត្តម | លោក ឡៅ ជុនធី |
| លោក Michael G.KARNAVAS | កញ្ញា SILKE Studzinsky |
| លោក ផាត់ ពៅសៀង | លោក គង់ ពិសី |
| កញ្ញា Diana ELLIS | លោក ហុង គឹមសួន |
| លោក ស សូវាន | លោក យ៉ុង ផានិត |
| លោក Jacques VERGÈS | លោកស្រី ស៊ីន សុវ៉ន |
| លោក Philippe GRÉCIANO | លោក Mahdev MOHAN |
| លោក សុន អរុណ | លោកស្រី NGUYEN Lyma |
| លោក Michiel PESTMAN | លោកស្រី Marie GUIRAUD |
| លោក Victor KOPPE | លោក Patrick BAUDOUIN |
| | លោក Olivier BAHOUGNE |

00613328



## ការយល់ឃើញ

១. នៅក្នុងករណីនេះ ជនជាប់ចោទទាំងបួន(៤)រូប បានជូនដំណឹងពីបំណងប្ដឹងឧទ្ធរណ៍របស់ពួកខ្លួនទៅនឹងដីកាដំណោះស្រាយ[1] ។ ក្រោយមកទៀត អង្គបុរេជំនុំជម្រះ បានអនុញ្ញាតឱ្យ អៀង សារី ដាក់សារណាបណ្ដឹងឧទ្ធរណ៍របស់គាត់កុំឱ្យលើសពីចំនួនមួយរយប៉ែតសិប(១៨០)ទំព័រ[2] ។ ខណៈ ពេលដែលធ្វើដូច្នោះ អង្គបុរេជំនុំជម្រះ បានទទួលស្គាល់ថា "ភាពស្មុគស្មាញ" នៃបញ្ហាយុត្តាធិការ ជាច្រើនដែល អៀង សារី បានកំណត់អត្តសញ្ញាណបាននៅក្នុងដីកាដំណោះស្រាយ បង្កើតបានជា "កាលៈទេសៈលើកលែង" ដែលធានាដល់ការបន្ថែមចំនួនទំព័រនេះ[3] ។ អង្គបុរេ ជំនុំជម្រះ បានកត់សម្គាល់ថា សហព្រះរាជអាជ្ញា "នឹងត្រូវបានផ្ដល់នូវកាលានុវត្តភាពដូចគ្នានេះដែរ" បើសិន ជាពួកគាត់ស្វែងរកនូវការសុំបន្ថែមចំនួនទំព័រកំណត់ ។ យោងតាម អង្គបុរេជំនុំជម្រះ ការណ៍នេះ នឹងផ្ដល់នូវ "ឯកសារគ្រប់គ្រាន់ដើម្បីពិចារណាលើគ្រប់បញ្ហាទាំងអស់ដែល បានលើកឡើងឱ្យបាន ត្រឹមត្រូវ"[4] ។

២. សហព្រះរាជអាជ្ញា បានពិនិត្យលើដីកាដំណោះស្រាយ ហើយបានលើកឡើងពីទឡ្ហីករណ៍នានានៃបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ។ ការណ៍នេះមិនអាចនឹងធ្វើការកំណត់បាន ថាតើនៅលើទឡ្ហីករណ៍អ្វីខ្លះដែលជនជាប់ចោទដទៃទៀតធ្វើការជំទាស់ទៅនឹងដីកាដំណោះស្រាយ ដោយហេតុ ថាព័ត៌មាននេះពុំត្រូវបានផ្ដល់ជូននៅក្នុងសេចក្ដីជូនដំណឹងពីការដាក់បណ្ដឹងឧទ្ធរណ៍នោះទេ ។ ទោះ ជាយ៉ាងដូច្នេះក៏ដោយ ដោយបានយល់ឃើញពីចរិតលក្ខណៈ វិសាលភាព និងទំហំនៃចម្លើយតប ជាសារធាតុ និងតាមនីតិវិធី ទៅនឹងទឡ្ហីករណ៍ នានា ដែល អៀង សារី បានលើក ឡើង និងការ ពិចារណាដែលថា ទឡ្ហីករណ៍របស់ជនជាប់ចោទទាំងបី(៣)នាក់ផ្សេងទៀតអាចនឹងមានការជាប់ ទាក់ទងគ្នានោះ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ដើម្បីជាផល ប្រយោជន៍នៃយុត្តិធម៌ ត្រូវដាក់ ចម្លើយតបរួមមួយទៅនឹងបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីទាំង អស់ដែល ជំទាស់រួមទៅនឹង ដីកាដំណោះស្រាយ ។

---

[1] នួន ជា (ការជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ ដែលបានជូនដំណឹងកាលពីថ្ងៃទី២៣ កញ្ញា ២០១០) ។ ខៀវ សំផន (អបជ-១០៤ ការជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ ដែលបានជូនដំណឹងកាលពីថ្ងៃទី២៣ កញ្ញា ២០១០) ។ អៀង ធីរិទ្ធ (ការជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ដែលបានជូនដំណឹងកាលពីថ្ងៃទី២០ កញ្ញា ២០១០) ។ អៀង សារី (អបជ-៧៥ ការជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ ដែលបានជូនដំណឹងកាលពីថ្ងៃទី២០ កញ្ញា ២០១០) ។ បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា នៅពុំទាន់បានដាក់លេខនៅឡើយទេ ។

[2] សាលដីកាលើសំណើបន្ទាន់បង្ហំរបស់ អៀង សារី ស្នើសុំបន្ថែមចំនួនទំព័រកំណត់ដើម្បីប្ដឹងឧទ្ធរណ៍ពីបញ្ហាយុត្តាធិការ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ។ បណ្ដឹងឧទ្ធរណ៍លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-៧៥), អង្គបុរេជំនុំជម្រះ, ថ្ងៃទី១ តុលា ២០១០ ("សាលដីការបស់ អបជ លើសំណើរបស់ អៀង សារី សុំបន្ថែមចំនួនទំព័រកំណត់"), ទំព័រទី ៤ ។

[3] សាលដីការបស់ អបជ លើសំណើរបស់ អៀង សារី សុំបន្ថែមចំនួនទំព័រកំណត់"), ទំព័រទី ១០ ។

[4] សាលដីការបស់ អបជ លើសំណើរបស់ អៀង សារី សុំបន្ថែមចំនួនទំព័រកំណត់"), ទំព័រទី ១១ ។

៣. ការណ៍នេះនឹងធានាពីសុចរិតភាពនៃសំអាង (integrity of argument) និងការប្រើប្រាស់មួយដែលមានការពិចារណាដ៏ហ្មត់ចត់នៃពេលវេលាកំណត់ក្នុងការឆ្លើយតប ជាពិសេស ពិចារណាទៅលើធនធានដែលមានកំណត់ និងដែលមានបន្ទុកធ្ងន់ធ្ងរលើសលប់ខ្លាំងក្នុងការបកប្រែភាសានៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ("កសព") និងនៅក្នុងផ្នែកគ្រប់គ្រងតុលាការ។ ពេលកន្លងមក ជាច្រើនលើកច្រើនសារហើយដែល អង្គបុរេជំនុំជម្រះ ធ្លាប់បានទទួលយកនូវ ចម្លើយតបរួមនានារបស់ សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍ ផ្សេងៗដែលជំទាស់ទៅនឹងដីកាទូទៅពីការសម្រេចសួរដេញដោល[5] ។ ចម្លើយតបរួមនេះ គឺជាករណីបែបដូច្នោះមួយទៀត។

៤. ដូចដែល អង្គបុរេជំនុំជម្រះ បានទទួលស្គាល់ហើយថា សហព្រះរាជអាជ្ញា ត្រូវការចាំបាច់នូវចំនួនទំព័រកំណត់មួយដែលស្មើនឹងចំនួនទំព័រ ដែលជនជាប់ចោទទាំងបួនរូបបានប្រើប្រាស់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ។ ទោះបីជាបណ្តឹងឧទ្ធរណ៍ទាំងនោះមិនទាន់ត្រូវបានដាក់នៅឡើយក្តី សហព្រះរាជអាជ្ញាចាត់ទុកថាសំណើនេះមិនមែន "មុនពេលកំណត់ពេក"[6] នោះដែរដោយសារតែដីកាសម្រេចមួយ ដែលអនុញ្ញាតយល់ព្រមជាមុន ឱ្យខ្លួនបន្ថែមនូវចំនួនទំព័រថែមពីលើចំនួនកំណត់នោះនឹងជួយដល់ខ្លួនក្នុងការត្រៀមរៀបចំ និងចាត់ចែងគ្រប់គ្រងលើការដាក់សារណាឆ្លើយតបរួមរបស់ខ្លួន។ ក្នុងការធ្វើសំណើសុំផ្តល់ការអនុញ្ញាតជាមុនដើម្បីបន្ថែមចំនួនទំព័រលើសពីការកំណត់នេះ សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា៖ ទី១) អង្គបុរេជំនុំជម្រះ មានពេលវេលាខ្លីចំនួនបួនខែ គិតចាប់តាំងពីថ្ងៃចេញដីកាដំណោះស្រាយដើម្បីធ្វើសេចក្តីសន្និដ្ឋានលើដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ទាំងនេះ, ទី២) សហព្រះរាជអាជ្ញា មានពេលវេលាតែដប់ប្រាំ (១៥)ថ្ងៃប៉ុណ្ណោះដើម្បីធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងនេះ ដែលក្នុងនោះគិតបញ្ចូលទាំងពេលវេលាសម្រាប់ធ្វើការបកប្រែភាសាផង, និងទី៣) លទ្ធភាពនៅក្នុងការបកប្រែរបស់ការិយាល័យសហព្រះរាជអាជ្ញា និងរបស់ផ្នែកគ្រប់គ្រងតុលាការ គឺមានបន្ទុកដ៏ធ្ងន់ធ្ងរលើសលប់ខ្លាំងដែលរឿងនេះកន្លងមកអង្គបុរេជំនុំជម្រះ ក៏ធ្លាប់បានទទួលស្គាល់រួចមកហើយដែរ[7] ។

---

[5] *សូមមើលជាឧទាហរណ៍,* សាលដីកាលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំបន្ថែមពេលវេលា និងចំនួនចំនួនទំព័រកំណត់ ក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, ខៀវ សំផន, អៀង សារី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនទៀត ដែលជំទាស់នឹងដីកាសម្រេចពីសហកម្មឧក្រិដ្ឋកម្មរួម, បណ្តឹងឧទ្ធរណ៍លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ ៣៥, ៣៧, ៣៨, ៣៩), អង្គបុរេ ជំនុំជម្រះ, ថ្ងៃទី៩ កុម្ភៈ ២០១០, ទំព័រទី ៤ ។ ការដាក់ឯកសារផ្សេងៗស្រដៀងគ្នានេះ ដែលត្រូវបានយល់ព្រមទទួលយកមានទាក់ទងនឹង បណ្តឹងឧទ្ធរណ៍ស្តីពី៖ ទី១) ឃ្លាំងផ្ទុកឯកសាររួម ("SMD"), ទី២) ភស្តុតាងដែលត្រូវចោទថាបានមកពីការធ្វើទារុណកម្ម, និងទី៣) បណ្តឹង ឧទ្ធរណ៍ផ្សេងៗលើបញ្ហាស្តីពីការចោទប្រកាន់ថាមានអំពើពុករលួយផ្នែករដ្ឋបាលនៅ អវតក ។

[6] ដីកាសម្រេចលើពាក្យសុំរបស់សហព្រះរាជអាជ្ញា ដែលសុំបន្ថែមចំនួនទំព័រថែមពីលើចំនួនកំណត់ដើម្បីដាក់ចម្លើយតបរបស់ខ្លួន, បណ្តឹងឧទ្ធរណ៍លេខ ០០២/១៩-០៩-២០០៧/ អវតក/កសចស (អបជ ២៦), អង្គបុរេជំនុំជម្រះ, ថ្ងៃទី៤ កញ្ញា ២០១០, កថាខណ្ឌ ទី៣ ។

[7] អ៊ីម៉ែលពីអង្គបុរេជំនុំជម្រះ ផ្ញើជូនមេធាវីការពារក្តីរបស់ ខៀវ សំផន ដែលបានចម្លងជូន សហព្រះរាជអាជ្ញា, ថ្ងៃទី១ តុលា ២០១០ ។

៥. សហព្រះរាជអាជ្ញា មិនមានបំណងធ្វើការគ្រោងទុកអំពីថា តើខ្លួនបំរុងនឹងដាក់នូវសំណួមពរឆ្លើយតបរួមរបស់ខ្លួននៅក្នុងរយៈពេលដប់ប្រាំថ្ងៃដែលមានស្រាប់ដែរ ឬអត់នោះទេ ។ ការប៉ាន់ប្រមាណ នេះនឹងត្រូវបានធ្វើការកំណត់ដោយផ្អែកទៅលើវិសាលភាព និងចំនួនទំព័រនៃសារណាបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងបួនរូប និងទៅលើលទ្ធភាពរបស់ផ្នែកគ្រប់គ្រងតុលាការក្នុងការបកប្រែភាសាចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ នៅក្នុងរយៈពេលប៉ុន្មានថ្ងៃទៀតនេះ ។ បើសិនជាចាំបាច់នោះ សហព្រះរាជអាជ្ញានឹងធ្វើសំណើសុំបន្ថែមចំនួនទំព័រ អង្គបុរេជំនុំជម្រះភ្លាមបន្ទាប់ពីបានទទួលនូវសារណានេះ ។ ប៉ុន្តែចំពោះមុខនេះ សហព្រះរាជអាជ្ញា គ្រាន់តែសូមស្នើឲ្យអង្គបុរេជំនុំជម្រះ ចេញដីការសម្រេចថា រយៈពេលកំណត់សម្រាប់ការដាក់ចម្លើយតបរួមទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍គឺចាប់ផ្ដើមគិតចាប់តាំងពីថ្ងៃដែល សហព្រះរាជអាជ្ញាបានទទួលនូវសារណាបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងអស់ ជាភាសាអង់គ្លេស និងភាសាខ្មែរ។

## សេចក្ដីសន្និដ្ឋាន

៦. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គបុរេជំនុំជម្រះ៖ ទី១) អនុញ្ញាតឲ្យខ្លួនដាក់ចម្លើយតបរួមមួយ ទៅនឹងរាល់សំណួមពរក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់មេធាវីការពារក្ដីទាំងអស់, ទី២) ផ្ដល់ការអនុញ្ញាតឲ្យបន្ថែមចំនួនទំព័រថែមពីលើចំនួនកំណត់ដែលស្មើនឹងចំនួនទំព័រនៃបណ្ដឹងឧទ្ធរណ៍ទាំងអស់របស់មេធាវីរួមបញ្ចូលគ្នា[8], និង ទី៣) ចេញដីកាសម្រេចអំពីពេលវេលាកំណត់សម្រាប់ការដាក់ចម្លើយតបរួម ដែលចាប់ផ្ដើមគិតចាប់តាំងពីពេលដែលសហព្រះរាជអាជ្ញា ទទួលបាននូវសារណាបណ្ដឹងឧទ្ធរណ៍គ្រប់ទាំងបួន ជាភាសាអង់គ្លេស និងភាសាខ្មែរ[9] ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | |
| | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | | |

[8] ការបន្ថែមចំនួនទំព័រថែមពីលើចំនួនកំណត់អាចត្រូវបានអនុញ្ញាតដោយ អង្គបុរេជំនុំជម្រះ តាមមាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អវតក, អវតក០០១/២០០៧ /វិសោធនកម្មលើកទី៤ ។

[9] ការសុំពន្យាពេលបន្ថែមពីលើពេវេលាកំណត់អាចត្រូវបានអនុញ្ញាតដោយ អង្គបុរេជំនុំជម្រះ តាមវិធាន៣៩.៤.ក នៃវិធានផ្ទៃក្នុង ។